**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
លេខ ៤៥២១៧ ព.ណ.[illegible]

ភ្នំពេញ, ថ្ងៃទី ២១ ខែ ១០ ឆ្នាំ ២០១១

## សូមគោរពជូន

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងទេសចរណ៍**
- **លោកជំទាវរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី**
- **ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**
- **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**
- **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកគយ និងរដ្ឋាករកម្ពុជា**
- **ឯកឧត្តម នាយកសាលាតូមិន្ទ រដ្ឋបាល**

**កម្មវត្ថុ** ៖ កិច្ចប្រជុំលើកទី ១៤ របស់គណៈកម្មាការអនុវត្តគម្រោង និងក្រុមការងារសម្រាប់អនុវត្តន៍មូលនិធិពហុភាគីនិងសម្របសម្រួលអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម(Trade SWAp) ។
**ជូនភ្ជាប់** ៖ របៀបវារៈនៃកិច្ចប្រជុំ ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន ឯកឧត្តម លោកជំទាវ មេត្តាជ្រាបថា ដើម្បីជំរុញការអនុវត្ត Trade SWAp ឲ្យមានសន្ទុះតាមការគ្រោងទុក ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញសមាជិកនៃគណៈកម្មការអនុវត្តគម្រោង IC (Implementation Committee) និងក្រុមការងារសម្រាប់អនុវត្តន៍ការងារមូលនិធិពហុភាគី និងសម្របសម្រួលអភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម (Trade SWAp) ចូលរួមប្រជុំលើកទី១៤ របស់គណៈកម្មការអនុវត្តគម្រោង ប្រចាំខែតុលា ដើម្បី "ពិនិត្យបច្ចុប្បន្នភាព នៃការអនុវត្តកម្មវិធីTDSP, ពិនិត្យលើមូលដ្ឋានគ្រឹះនៃផែនទីបង្ហាញផ្លូវសរសរស្តម្ភទាំងបី និងបញ្ហានានា" ដូចមានជូនភ្ជាប់ក្នុងរបៀបវារៈ ។ កិច្ចប្រជុំនេះ នឹងប្រព្រឹត្តទៅនៅ ថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០១១ វេលាម៉ោង១៤:៣០នាទី នៅសាលប្រជុំក្រសួងពាណិជ្ជកម្ម , ក្រោមអធិបតីភាព **ឯកឧត្តម ប៉ាន សូរស័ក្តិ** រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការអនុវត្តគម្រោង ។

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** មេត្តាចាត់បញ្ជូន ឯកឧត្តម លោកជំទាវ ដែលជាសមាជិកនៃគណៈកម្មការអនុវត្តគម្រោង និងក្រុមការងារសម្រាប់អនុវត្តន៍មូលនិធិពហុភាគី និងសម្របសម្រួលអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម ចូលរួមប្រជុំតាមការកំណត់ខាងលើដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

រដ្ឋលេខាធិការ

កើត_សុខណៃ

__ចម្លងជូន__
- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី
- ឯកឧត្តម សុខ សុភ័ក្ត្រ
- ឯកសារ-កាលប្បវត្តិ

__ទំនាក់ទំនងនាយកដ្ឋានសហប្រតិបត្តិការជាតិ:__
ទូរស័ព្ទ: ០១២ ៨០៤ ២៣០ (ម៉ម ម៉ានី)
អ៊ីម៉ែល:manymamkh@yahoo.com